ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Inform-អជក 09-06-14 ថ/-ប/ល-P.63

អគ្គិសនីកម្ពុជា

លេខ : ...

# សេចក្តីជូនដំណឹង

## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជាសូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក ចំនួន ០២ រូប ដើម្បីចូលបម្រើការងារនៅ ការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ នៃនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃអគ្គិសនីកម្ពុជា។

* - **លក្ខណៈសម្បត្តិបេក្ខជន** :

I - សម្រាប់ បុគ្គលិកព័ត៌មានវិទ្យា ចំនួន ០១ រូប :

- បេក្ខជនទាំង ០២ ភេទ, ត្រូវមានអាយុចាប់ពី ១៨ ដល់ ៣៥ឆ្នាំ (គិតត្រឹមថ្ងៃឈប់ទទួលពាក្យ)
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតជំនាញ : បរិញ្ញាបត្រព័ត៌មានវិទ្យា ឡើងទៅ និងចេះ GIS, AutoCad, Network និង ថែទាំ Hardware Software
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ជាមធ្យម ។

II- សម្រាប់ បុគ្គលិកសន្តិសុខ ចំនួន ០១ រូប :

- បេក្ខជនភេទប្រុស, ត្រូវមានអាយុចាប់ពី ១៨ ដល់ ៣៥ឆ្នាំ (គិតត្រឹមថ្ងៃឈប់ទទួលពាក្យ)
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.VI.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតវប្បធម៌ : ចាប់ពី សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឡើងទៅ
- បេក្ខជន ត្រូវមានការយសម្បទាមាំមួន ។

* - **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលបម្រើការងារ មានបិទតែមប្រ៏(១.០០០ រៀល) ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬអាចយក សៀវភៅគ្រួសារឬអត្តសញ្ញាណប័ណ្ណ(ច្បាប់ចម្លងមានបញ្ជាក់ពី សាលារាជធានីភ្នំពេញ ឬសាលាខេត្ត)ឬលិខិតបញ្ជាក់ទីលំនៅ ចុះហត្ថលេខាពីខណ្ឌ-ស្រុក ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់កិរិយាមារយាទ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់សុខភាព(ចេញដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ)ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ មានបញ្ជាក់ពីសាលារាជធានីភ្នំពេញ ឬសាលាខេត្ត ចំនួន ០១ ច្បាប់

- តារាងពិន្ទុ ( TRANSCRIPT ) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ ឬ ច្បាប់ចម្លងសញ្ញាប័ត្រផ្សេងៗ (បើមាន) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ (បើមាន) ចំនួន ០១ ច្បាប់

*- **ទីកន្លែងទទួលពាក្យ** : សាលប្រជុំអគារ C ជាន់ទី៣ នៃអគ្គិសនីកម្ពុជា

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០
- ពាក្យសុំចូលបម្រើការងារ ត្រូវប្រើប្រាស់គំរូ មានបោះត្រាសម្គាល់របស់អគ្គិសនីកម្ពុជា។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤

ជ. ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា

ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា

អគ្គនាយករង

អេង_ភក្តា

ELECTRICITE DU CAMBODGE